# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល

សំណុំរឿងរដ្ឋប្បវេណីលេខ៖ ៨២៧ រប
ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២១
សញ្ញាណរឿងក្ដី៖ ប្ដឹងសុំលែងលះ
សាលក្រមរដ្ឋប្បវេណីលេខ៖ ១៣៦ “ណ”
ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២១

## តាមនាមប្រជារាស្ត្រខ្មែរ

សាលាដំបូងខេត្តកណ្ដាល បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២១ ។

## ចៅក្រមជំនុំជម្រះ

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្ដាល

## ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted] ក្រឡាបញ្ជី

## សាលាដំបូងខេត្តកណ្ដាល

សាលាដំបូងខេត្តកណ្ដាល បានចេញសាលក្រមដែលមានគូភាគីដូចខាងក្រោម:

**-ដើមចោទ:** ឈ្មោះ [redacted] ស៊ាងលី ភេទស្រី កើតឆ្នាំ១៩៧៧ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ។

តំណាងដោយអាណត្តិ៖លោកស្រីមេធាវី [redacted] លោកមេធាវី [redacted] ។

**-ចុងចម្លើយ:** ឈ្មោះ [redacted] ទីន ភេទប្រុស កើតឆ្នាំ១៩៨០ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិ[redacted]។

តំណាងដោយអាណត្តិ៖គ្មាន។

**- កម្មវត្ថុ: សុំលែងលះ និងសុំសិទ្ធិគ្រប់គ្រងលើកូនឈ្មោះ [redacted] វណ្ណនៈ កើតឆ្នាំ២០០៣**

## អង្គហេតុ និងចំណុចវិវាទ

១. ការពន្យល់ត្រួសៗអំពីរឿងក្ដី

ដើមចោទឈ្មោះ [redacted] ស៊ាងលី និងចុងចម្លើយឈ្មោះ [redacted] ទីន បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាតាមប្រពៃណីតាំងពីឆ្នាំ១៩៩៧ តែមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមផ្លូវច្បាប់ទេ ។ ក្នុងការរួមរស់នៅជាមួយ



Scanned with CamScanner

គ្នានេះមានកូនប្រុស ០១នាក់ ឈ្មោះ [redacted] វណ្ណន: កើតឆ្នាំ២០០៣ ។ រហូតដល់ក្នុងអំឡុងពេល ០២ឆ្នាំ កន្លងមកនេះដើមចោទឈ្មោះ [redacted] ស៊ាងលី និងចុងចម្លើយឈ្មោះ [redacted] នីន រស់នៅជាមួយគ្នាមិនចុះសម្រុងគ្នា ចេះតែរកាំរកូសនឹងគ្នាជាប្រចាំដែលជាមូលហេតុធ្វើឱ្យអ្នកទាំងពីរអស់មនោសញ្ចេតនា និងមិនអាចរស់នៅជាមួយគ្នាទៀតបាន ។

២. អង្គហេតុដែលជាមូលហេតុនៃការទាមទារ

មូលហេតុដែលដើមចោទប្តឹងសុំលែងលះចុងចម្លើយឈ្មោះ [redacted] នីន ដោយសារតែការរស់នៅមិនចុះសម្រុងគ្នា មានភាពរកាំរកូសរហូតដល់ពុំអាចរស់នៅជាមួយគ្នាទៀតបាន ។

៣. សាលក្រមដែលទាមទារដោយដើមចោទ

- ប្តឹងសុំលែងលះប្តីឈ្មោះ [redacted] នីន
- សុំសិទ្ធិគ្រប់គ្រងលើកូនប្រុសឈ្មោះ [redacted] វណ្ណន: ភេទប្រុស កើតឆ្នាំ២០០៣ ។

៤. ការអះអាងរបស់ដើមចោទ និងសេចក្តីថ្លែងការណ៍របស់មេធាវីតំណាងដោយអាណត្តិ

ដើមចោទឈ្មោះ [redacted] ស៊ាងលី បានអះអាងថា: ខ្លួនបានរៀបអាពាហ៍ពិពាហ៍តាំងពីឆ្នាំ១៩៨៧ មកម្លេះតែមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍នោះទេ ក្នុងការរស់នៅជាមួយគ្នានេះមានកូនប្រុស ០១នាក់ឈ្មោះ [redacted] វណ្ណន: ។ រហូតដល់អំឡុងពេល ០២ឆ្នាំកន្លងទៅនេះ ការរស់នៅចេះតែមិនចុះសម្រុងនឹងគ្នា និងមានភាពរកាំរកូសរហូតដល់ពុំអាចរស់នៅជាមួយគ្នាបាន ទើបដើមចោទឈ្មោះ [redacted] ស៊ាងលី សម្រេចចិត្តដាក់ពាក្យបណ្តឹងលែងលះពីឈ្មោះ [redacted] នីន និងស្នើសុំឱ្យតុលាការសម្រេចលើការទាមទារដូចខាងក្រោម៖

- ប្តឹងសុំលែងលះពីឈ្មោះ [redacted] នីន
- សុំសិទ្ធិគ្រប់គ្រងលើកូនប្រុសឈ្មោះ [redacted] វណ្ណន: ។

មេធាវី [redacted] និងមេធាវី [redacted] បានធ្វើសេចក្តីថ្លែងការណ៍ថា: កូនក្តីរបស់ខ្លួនបានរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីតាំងពីឆ្នាំ១៩៨៧ មកម្លេះ ក្នុងការរស់នៅនេះមានកូនប្រុស ០១នាក់ឈ្មោះ [redacted] វណ្ណន: ។ ការរស់នៅនេះចេះតែមិនចុះសម្រុងនឹងគ្នា និងមានភាពរកាំរកូសរហូតដល់មិនអាចរស់នៅជាមួយគ្នាបាន ហេតុដូច្នេះស្នើសុំឱ្យតុលាការមេត្តាពិចារណា និងសម្រេចឱ្យកូនក្តីខ្លួនបានលែងលះពីឈ្មោះ [redacted] នីន និងឱ្យកូនក្តីយើងខ្ញុំជាអ្នកមានអំណាចមេបាលើឈ្មោះ [redacted] វណ្ណន: ។

៥. ការអះអាងរបស់ចុងចម្លើយ

ចុងចម្លើយឈ្មោះ [redacted] នីន បានអះអាងថា: ខ្លួនមិនឯកភាពតាមការទាមទាររបស់ដើមចោទទេ ។ ខ្លួនស្នើសុំសិទ្ធិគ្រប់គ្រងកូនប្រុសឈ្មោះ [redacted] វណ្ណន: ។

៦. ភស្តុតាងជាឯកសាររួមមាន:

-សំបុត្របញ្ជាក់កំណើតលេខ ២០៨ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៩ របស់ឈ្មោះ [redacted] វណ្ណន: ចេញដោយលោកឃុំដីឥដ្ឋ ។ (មួយច្បាប់ថតចម្លង)

-សំបុត្របញ្ជាក់កំណើតលេខ ៣៥០ ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១២ របស់ឈ្មោះ [redacted] ស៊ាងលី ចេញដោយលោកមេឃុំដីឥដ្ឋ ។ (មួយច្បាប់ថតចម្លង)

-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ [redacted] ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៦ របស់ឈ្មោះ [redacted] ស៊ាងលី ។ (មួយច្បាប់ថតចម្លង)

-អត្តសញ្ញាណប័ណ្ណសញ្ញាតិខ្មែរលេខ [redacted] ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៦ របស់ឈ្មោះ [redacted] នីន ។ (មួយច្បាប់ថតចម្លង)

-សៀវភៅស្នាក់លេខ ២០៧៧ ដ.ឥ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១២ ចេញដោយអធិការដ្ឋាននគរបាលស្រុកកៀនស្វាយ ។ (មួយច្បាប់ថតចម្លង)

ក្រោយពីបានស្តាប់សេចក្តីថ្លែងការណ៍របស់ភាគីដើមចោទ

ក្រោយពីបានស្តាប់សេចក្តីថ្លែងការណ៍របស់ភាគីចុងចម្លើយ

ក្រោយពីថយទៅពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១. ចំពោះការប្តឹងសុំលែងលះប្តី

_ក្រោយពីបានធ្វើការសាកសួរភាគីដើមចោទ ធ្វើការផ្សះផ្សា និងធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងពិនិត្យភស្តុតាងក្នុងនីតិវិធីទាញហេតុផលផ្ទាល់មាត់ តុលាការយល់ឃើញថា: គូភាគីពិតជាបានរួមរស់ជាមួយគ្នាជាអនីតិសង្វាសជន ដោយពុំមានចុះសំបុត្រអាពាហ៍ពិពាហ៍ ពិតប្រាកដមែន ។

_ដើមចោទអស់មនោសញ្ចេតនាក្នុងការរួមរស់ជាមួយគ្នាតទៅទៀតបាន ដោយសារតែការរស់នៅជាមួយគ្នាកន្លងមកពុំសូវចុះសម្រុងគ្នា ជាហេតុធ្វើឱ្យខ្លួនមិនអាចរួមរស់ជាមួយគ្នាតទៅទៀតបាន ដូច្នេះតុលាការចាត់ទុកថាកត្តាទាំងអស់ខាងលើនេះជាមូលហេតុនៃការលែងលះគ្នា តាមបញ្ញត្តិមាត្រា ៩៧៨ ចំណុច ១.ង នៃក្រមរដ្ឋប្បវេណី ។

_តាមការសួរដេញដោល នៅក្នុងនីតិវិធីទាញហេតុផលផ្ទាល់មាត់បញ្ជាក់ថា ភាគីដើមចោទ និងចុងចម្លើយបានរៀបការតាំងពីឆ្នាំ១៩៩៧ មកម្លេះ ហើយគូភាគីបានរួមរស់ជាមួយគ្នា មានកូនប្រុសមួយនាក់ឈ្មោះ [redacted] វណ្ណុន: ភេទប្រុស កើតថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៣ តែដោយការរស់នៅមិនចុះសម្រុងគ្នា ជាហេតុធ្វើឱ្យខ្លួនមិនអាចរួមរស់ជាមួយគ្នាតទៅទៀតបាន ។

-សំបុត្របញ្ជាក់កំណើតលេខ ២០៨ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៩ របស់ឈ្មោះ [redacted] វណ្ណុន: ចេញដោយលោកឃុំដីឥដ្ឋ ។ (មួយច្បាប់ថតចម្លង)

-សំបុត្របញ្ជាក់កំណើតលេខ ៣៥០ ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១២ របស់ឈ្មោះ [redacted] ស៊ាងលី ចេញដោយលោកមេឃុំដីឥដ្ឋ ។ (មួយច្បាប់ថតចម្លង)

-អត្តសញ្ញាណប័ណ្ណសញ្ញាតិខ្មែរលេខ ០២១០០៥៨៩១ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៦ របស់ឈ្មោះ [redacted] ស៊ាងលី ។ (មួយច្បាប់ថតចម្លង)

-អត្តសញ្ញាណប័ណ្ណសញ្ញាតិខ្មែរលេខ ០២១១៨០២៧២ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៦ របស់ឈ្មោះ [redacted] នីន ។ (មួយច្បាប់ថតចម្លង)

-សៀវភៅស្នាក់លេខ ២០៧៧ ដ.ឥ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១២ ចេញដោយអធិការដ្ឋាននគរបាលស្រុកកៀនស្វាយ ។ (មួយច្បាប់ថតចម្លង)

_ផ្អែកតាមសំអាងហេតុខាងលើនេះ ការទាមទាររបស់ដើមចោទមានមូលដ្ឋានសំអាងត្រឹមត្រូវតាមច្បាប់ គប្បីតុលាការទទួលស្គាល់នូវការទាមទារនេះ ។

២. ចំពោះការទាមទារសិទ្ធគ្រប់គ្រងកូន

–តាមសំបុត្របញ្ជាក់កំណើតលេខ: ២០៨ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៩ របស់ឈ្មោះ [redacted] វណ្ណុន: អាច បញ្ជាក់បានថាឈ្មោះ [redacted] វណ្ណុន: ពិតជាកូនរបស់ដើមចោទ និងចុងចម្លើយប្រាកដមែន។

–ដើមចោទ បានប្តឹងសុំគ្រប់គ្រងកូនប្រុសឈ្មោះ [redacted] វណ្ណុន: ភេទប្រុស កើតថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៣ ។

–ចុងចម្លើយ បានប្តឹងសុំសិទ្ធិគ្រប់គ្រងកូនស្រីស្រីឈ្មោះ [redacted] វណ្ណុន: ភេទប្រុស កើតថ្ងៃទី០២ ខែសីហា ឆ្នាំ២០០៣ ។

តុលាការយល់ឃើញថា ដើមចោទទាមទារសិទ្ធិគ្រប់គ្រងកូនឈ្មោះ [redacted] វណ្ណុន: ភេទប្រុស កើតថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៣ គឺមានអត្ថិភាព គប្បីតុលាការលើកយកមកពិចារណា និងសម្រេចតាមការទាមទារ។

-ប្រាក់ប្រដាប់ក្តីត្រូវអនុវត្តតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា។

## សេចក្តីសម្រេចបញ្ចប់

១-ឱ្យដើមចោទឈ្មោះ [redacted] ស៊ាងលី និងចុងចម្លើយឈ្មោះ [redacted] ធីន លែងលះគ្នាគិតចាប់ពីថ្ងៃសាលក្រម ចូលជាស្ថាពរ ។

២-ឱ្យដើមចោទឈ្មោះ [redacted] ស៊ាងលី ភេទស្រី ជាអ្នកមានអំណាចមេបាលើកូនប្រុសឈ្មោះ [redacted] វណ្ណុន: ភេទប្រុស កើតថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៣ ។

៣-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ ។

សាលក្រមនេះទាញហេតុផលផ្ទាល់មាត់ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២១ ចំពោះមុខ ដើមចោទឈ្មោះ [redacted] ស៊ាងលី និងចុងចម្លើយឈ្មោះ [redacted] ធីន ។

ទុកសិទ្ធិឱ្យគូភាគីប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

ថ្ងៃព្រហស្បតិ៍ ១២កើត ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥

កណ្តាល, ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២១

**ចៅក្រម**

ហត្ថលេខា និងត្រា [redacted]

---

"បានចម្លងត្រឹមត្រូវតាមសាលក្រមដើម"

ថ្ងៃព្រហស្បតិ៍ ១២កើត ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥

កណ្តាល, ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២១

**ក្រឡាបញ្ជី**

បានឃើញ

**ចៅក្រម**

[redacted]

[redacted]